# មេរៀនទី៦០៖ ពួកសិស្សដើរតាមព្រះយេស៊ូវ

## ម៉ាកុស ១៖១៤-២០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ua5P8j2G7nE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/U7CKFdgbsZc

**គោលបំណង៖** ដើរតាមព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ ម៉ាកុស ១៖១៧** *“ទ្រង់មានព្រះបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឲ្យអ្នក នេសាទមនុស្សវិញ”។*

**ចំរៀង** ( *យូធូបលីង* )៖

១.ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo

២.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc

៣. ពេត្រុសអើយ https://youtu.be/ASM21vLgdf4

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ធ្វើតាមខ្ញុំ»**



១.សូមជ្រើសរើសសិស្ស២-៣នាក់ ហើយឲ្យពួកគេឡើងមកខាងមុខដើម្បីធ្វើជាអ្នកដឹកនាំ។

២.ឲ្យកុមារធ្វើជាអ្នកដឹកនាំ(ម្តងម្នាក់) ដោយឲ្យគេធ្វើអ្វីមួយហើយឲ្យអ្នកផ្សេងទៀតធ្វើតាម។ អាចជាការឈរជើងមួយ ធ្វើកាយវិកាយបក្សី រមៀល លើឥដ្ឋ ឬក៏ធ្វើអ្វីផ្សេងទៀតដែលអាចឲ្យកុមារដទៃធ្វើតាមបាន។

៣. សូមឲ្យកុមារដែលជាអ្នកដឹកនាំផ្សេងទៀតធ្វើកាយវិការផ្សេងម្តង ។

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាមិនមែនជារឿងងាយស្រួលនោះទេ ក្នុងការដើរតាមអ្នកដឹកនាំ ប៉ុន្តែយើងត្រូវតែព្យាយាមឲ្យអស់ពីសមត្ថភាព ក្នុងការដើរតាមអ្នកដឹកនាំដ៏ពិតរបស់យើងគឺអម្ចាស់ព្រះយេស៊ូវគ្រីស្ទ!

**៤. ការណែនាំមេរៀន**

គ្រូសូមនាំកុមារដើរនៅក្នុងថ្នាក់រៀន ដោយឲ្យពួកគេដើរពីក្រោយគ្រូ គ្រូដើរផងស្រែកប្រាប់កុមារផង បើគ្រូស្រែកថា ដើរលឿន កុមារត្រូវឲ្យលឿន បើគ្រូស្រែកថាដើរមួយៗ កុមារត្រូវដើរមួយៗ គ្រូស្រែកថាឈប់ ពួកគេត្រូវឈប់



ដើរ។ គ្រូស្រែកដើរដំណើរស្វា កុមារត្រូវដើរដំណើរស្វា ហើយបើគ្រូស្រែកដើរដំណើរសត្វទា ពួកគេត្រូវដើរដំណើរទា។គ្រូត្រូវផ្លាស់ប្តូរដំណើរឲ្យលឿន ដើម្បីឲ្យកុមារឆាប់ហត់ដល់កុមារហត់ សូមឲ្យពួកគេអង្គុយចុះ។

គ្រូនិយាយទៅកុមារថា នៅថ្ងៃនេះព្រះយេស៊ូវបានត្រាស់ហៅ បុរសមួយចំនួនក្នុងការដើរតាមទ្រង់។ តោះសូមឲ្យយើងបានស្វែងយល់ពីរបៀបដែលពួកគាត់បាន ឆ្លើយតបជាមួយ ព្រះយេស៊ូវ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅថ្ងៃនេះ ព្រះយេស៊ូវបានជួបជុំពួកសាវករបស់ទ្រង់។ ពួកសាវកគឺដូចជាសិស្សអីចឹង ហើយនៅក្នុងជំនាន់ព្រះយេស៊ូវ ពួកសិស្សបានព្យាយាមស្វែងរកគ្រូក្នុងការរៀនសូត្រនូវអ្វីដែលថ្មី។ ប៉ុន្តែនៅក្នុងសាច់រឿងនេះព្រះយេស៊ូវជាអ្នកដែលស្វែងរកសិស្សទៅវិញ។

សិស្សរបស់ទ្រង់ខ្លះព្រះអង្គបានជ្រើសរើសពីអ្នកនេសាទត្រី។ ព្រះយេស៊ូវបានមក ហើយឃើញពួកគេកំពុងនេសាទត្រី ហើយទ្រង់បានត្រាស់ហៅពួកគេឲ្យដើរតាមទ្រង់វិញ។ ព្រះអង្គបានមានបន្ទូលថា ពួកគេនឹងនេសាទមនុស្សវិញម្តង! ស្តាប់ទៅវាដូចជាចម្លែកបន្តិច មែនអត់? ប៉ុន្តែសូមឲ្យយើសាកទាយទៅមើលថា តើពួក សិស្សបានធ្វើអ្វី? ពួកសិស្សមិនបានសុំឲ្យព្រះយេស៊ូវឈប់ចាំពួកគេនេសាទរួចសិននោះទេ។ ពួកគេ មិនទាំងបានសួរព្រះយេស៊ូវថា តើទ្រង់ចង់សំដៅទៅលើអ្វីអំពីការនេសាទមនុស្សនោះ។ នៅក្នុងព្រះគម្ពីរ បាននិយាយថា “រំពេចនោះ” ពួកសិស្សបានទំលាក់អួនចុះហើយដើរតាមព្រះយេស៊ូវ។

ពួកគេមិនបានដឹងថាជីវិតរបស់ពួកគេនឹងទៅជាយ៉ាងណានោះទេ។ គេមិនដឹងថាលោកគ្រូរបស់ពួកគេនឹងត្រូវស្លាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ឬក៏សមាជិករបស់ពួកគេអាចនឹងត្រូវស្លាប់ ដោយព្រោះតែសេចក្តីជំនឿចំពោះព្រះជាម្ចាស់ឡើយ។ ប៉ុន្តែពួកគេដឹងថា ការដែលដើរតាមព្រះយេស៊ូវពិតជាមានសារៈសំខាន់ខ្លាំងណាស់ ហើយនោះវាគឺជាអ្វីដែលពួកគាត់ត្រូវតែធ្វើ។ ពួកគាត់សុខចិត្តប្រថុយប្រថាន ដោយការទម្លាក់ចោលនូវកិច្ចការផ្សេងៗ ហើយចំណាយពេលតែជាមួយនឹងព្រះមេស៊ីតែប៉ុណ្ណោះ ក្នុងកំឡុងពេលដែលពួកគេអាចធ្វើវាបាន។ ពួកគេដឹងថា ការធ្វើបែបនេះគឺពិតជាមានន័យជាជាងកិច្ចការទាំងអស់ដែលពួកគេកំពុងធ្វើ។

ហើយចុះពួកយើងវិញ? ពួកយើងត្រូវតែទុកព្រះជាម្ចាស់ជាជម្រើសដំបូងបំផុតនៅក្នុងជីវិតរស់នៅរបស់ពួកយើង។ យើងត្រូវតែហ៊ានលះបង់នូវរបស់មួយចំនួន ដើម្បីឲ្យយើងអាចបម្រើទ្រង់អស់ពីចិត្តរបស់ពួកយើង។ តើអ្នកដឹងទេ?វាពិតជាមានតម្លៃណាស់! ជីវិតដើរតាមព្រះយេស៊ូវគឺមានតម្លៃជាងអ្វីទាំងអស់ដែលយើងអាចធ្វើឬក៏ស្រម៉ៃអំពីវា។ ការដើរតាមព្រះយេស៊ូវវាមិនងាយស្រួលរហូតនោះទេ ប៉ុន្តែទ្រង់បាននាំមកឲ្យយើងនូវ សេចក្តីអំណរ សន្តិភាព និងជីវិតអស់កល្បយ៉ាងពិតប្រាកដ។ ព្រះយេស៊ូវបានសន្យាថាទ្រង់នឹងនៅជាមួយយើងហើយ ផ្គត់ផ្គង់សម្រាប់យើង។ ព្រះអង្គប្រើយើងជាអ្នកចែករំលែកសេចក្តីស្រលាញ់និងដំណឹងល្អរបស់ទ្រង់។ ដូច្នេះសូមឲ្យយើងមានជំនឿលើទ្រង់។ ជឿលើសេចក្តីបង្រៀនរបស់ព្រះអង្គ ហើយត្រូវតែត្រៀមខ្លួនរួចជាស្រេចក្នុងការស្តាប់បង្គាប់និងដើរតាមព្រះយេស៊ូវ។ វាគឺពិតជាមានតម្លៃខ្លាំងណាស់។

### ៦. សំនួរពិភាក្សា

១. តើសាវកគឺជាអ្វី? *(សិស្ស)*

២.តើពួកអ្នកនេសាទត្រីធ្វើដូចម្ដេចនៅពេលដែលព្រះយេស៊ូវត្រាស់ហៅពួកគេឲ្យដើរតាមទ្រង់? *(ពួកគេបានដើរតាមទ្រង់មួយរំពេច)*

៣. តើព្រះយេស៊ូវបានមានបន្ទូលថានឹងបង្រៀនពួកគេឲ្យធ្វើអ្វី?*(អ្នកនេសាទមនុស្ស)*

៤. តើអ្នកគិតថាការនេសាទមនុស្សមានន័យដូចម្ដេច? *( បង្រៀនអ្នកដទៃអំពីព្រះយេស៊ូវ)*

៥. ព្រះយេស៊ូវបានត្រាស់ហៅយើងគ្រប់គ្នាឲ្យដើរតាមព្រះអង្គនៅថ្ងៃនេះ។ តើអ្នកនឹងឆ្លើយដូចម្ដេច? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

### ៧. ល្បែងកំសាន្ត «បង់សំណាញ់»



១. ព្រះយេស៊ូវចង់ឲ្យយើងក្លាយទៅជាអ្នកនេសាទមនុស្ស។ នេះគឺមានន័យថាយើងត្រូវតែ "ឈោងចាប់" មនុស្សដោយសេចក្ដីស្រលាញ់របស់ព្រះយេស៊ូវ ដូច្នេះពួកគេអាចមកទទួលជឿព្រះយេស៊ូវបាន។

២. ចែកកុមារជា ២ក្រុម ដោយមួយក្រុមដើរតួជាសំណាញ់ ហើយមួយក្រុមទៀតដើរតួជាត្រី។

៣. ក្រុមដែលដើរតួជាសំណាញ់ត្រូវឈរជារង្វង់ ហើយកាន់ដៃគ្នា ហើយលើកឡើងលើ។

៤. ក្រុមត្រីត្រូវហែលចេញនិងចូលក្នុងរង្វង់ ប៉ុន្តែនៅពេលដែលគ្រូស្រែកថា "ចាប់ត្រី" ក្រុមសំណាញ់ត្រូវទំលាក់ដៃចុះក្រោម ដើម្បីកុំឲ្យត្រីហែលចេញពីក្នុងរង្វង់បាន។

### ៨. ខគម្ពីរចងចាំ

**ម៉ាកុស ១៖១៧** *"ទ្រង់មានព្រះបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឲ្យអ្នក នេសាទមនុស្សវិញ"។*

### ៩. ហត្ថកម្ម «តោះចាប់ត្រី!»

សម្ភារៈដែលត្រូវការ៖សូមបោះពុម្ពរូបអ្នកនេសាទជាមួយអួន(ទំព័រខាងក្រោម)ក្រដាសពណ៌ កន្ត្រៃ និងជ័រការ



១. សូមឲ្យក្រដាសរូបភាពអ្នកនេសាទជាមួយអួនទៅកុមារគ្រប់ៗគ្នាម្នាក់មួយសន្លឹក

២. ឲ្យក្រដាសពណ៌ទៅកុមារគ្រប់ៗគ្នា ហើយឲ្យពួកគេកាត់ចេញជារូបត្រីតូចៗហើយបិទភ្ជាប់ជាមួយអួន។

៣. សូមរំលឹកកុមារថា ព្រះយេស៊ូវចង់ឲ្យយើងដើរតាមទ្រង់និងធ្វើជាអ្នកនេសាទមនុស្សសម្រាប់ទ្រង់។



### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)
ព្រះយេស៊ូវបានត្រាស់ហៅយើងឲ្យដើរតាមទ្រង់ហើយធ្វើជាអ្នកនេសាទមនុស្ស។ ក្នុងនាមជាគ្រូបង្រៀនសាលាថ្ងៃអាទិត្យ អ្នកគឺបានបំពេញកាតព្វកិច្ចនេះទាំងពីរ! អ្នកបានដើរតាមព្រះយេស៊ូវ និងធ្វើការជាអ្នកនេសាទមនុស្សតាមរយៈការចែកចាយដំណឹងល្អជាមួយកុមារតូចៗ! នៅថ្ងៃនេះ សូមឲ្យអ្នកបានអធិស្ឋាន ទៅកាន់ព្រះដើម្បីទូលសូមនូវសេចក្តីជំនឿក្នុងការបន្តដំណើរជាមួយទ្រង់ និងប្រាជ្ញាក្នុងការបង្រៀន កុមារអំពីសេចក្តីស្រលាញ់របស់ព្រះអង្គ។

**ម៉ាកុស ១៖១៧** “ទ្រង់មានព្រះបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឲ្យអ្នកនេសាទមនុស្សវិញ” ។

